# ង

ង ព្យញ្ជនៈទី ៥ ក្នុងវគ្គទី ១ ជាកណ្ឋជៈ គឺមានសំឡេងក្នុងបំពង់ក, ជាវគ្គន្តៈ ឃោសៈ, រាប់ចូលក្នុងពួកព្យញ្ជនៈសម្លាប់ គឺ សម្លាប់ជា ង៏, បើនៅពីខាងមុខព្យញ្ជនៈអឃោសៈ ឬ ផ្ញើជើងជាមួយនឹងព្យញ្ជនៈអឃោសៈ មិនបាច់សម្លាប់ដោយ មូសិកទន្ត ក៏មានសំឡេងជា ង៏ ដែរ ដូចជា ក្ង, ក្ងក, ចង្វាយ, ឆ្ងាយ, ថ្ងង់, ថ្ងៃ, ផ្ងារ ជាដើម ។

ង គុ. ដែលកោងរំពត់ទៅខាងគល់ ឬ ខាងចុងតើយស្កៀត : ស្នែងគោងស្កៀត, ខ្ទងង, (បើឲ្យងាយមើល ងាយអាន គួរសរសេរ ស្នែងគោ-ងស្កៀត, ខ្ទង-ង) ។

ងក់ ១ ន. ឈើក្លក ឬ ដែកមូលក្រវិល មានខ្សែចំ ឬ ក្រពួរក្រពួញ ជាប់មាំ សម្រាប់កាយដែនដីឲ្យហោល ។

ងក់ ២ កិ. សព. បន្ទោនក្បាលចុះហើយងើយឡើង : ងក់ក្បាល ។ អង្គុយងក់ គឺអង្គុយងុក ។ ងក់ងើកៗ គឺងក់ញាក់ញ៉ើករឿយៗ ។

ង៉ក់ កិ. វិ. ពាក្យសម្រាប់បម្រើពាក្យឈប់ឥតសំរៀង ស្ងាត់ : ឈប់ង៉ក់, ខាំង៉ក់ គឺឈប់ ឬ ខាំដោយ ឈប់ស្ងៀមភ្លាមទាំងមិនឲ្យដឹងនៅ ។

ងងក់ កិ. វិ. ដែលងក់រឿយៗ : ដើរងងក់, ធ្វើការងងក់; ច្រើននិយាយចំពោះតែមនុស្សចាស់ ដែលដើរ ឬ ធ្វើការងើបៗ ងក់ៗ ដោយងក ។

ងងល់ ឧ. ពាក្យសម្រាប់និយាយផ្ទួននឹងពាក្យងងឹត : ងងឹតងងល់ គឺងងឹតពេក ។

ងងាស កិ. វិ. ឬ គុ. ដែលមានដំណើរងើបងើយ ឆកាត : ដើរងងាស; ដំណើរងងាស ។

ងង៉ិះងង៉ុះ ឬ ងង៉ិសងង៉ូស គុ. ឬ កិ. វិ. ដែលសំដែងកិរិយាគួរស ឲ្យឮសំឡេងង៉ិះង៉ុះមិនចង់ធ្វើតាមបង្គាប់ : កូនខ្ញុំនេះពិបាកប្រើណាស់ ក៏ចេះតែងង៉ិះងង៉ុះមកទៀត ។

ងង៉ឹសងងាស កិ. វិ. ដែលមានដំណើរងឹសងាស មិនរៀបរយ, ដែលទទឹសទទាសតាំងតែខ្លួនឯង : កុំដើរងង៉ឹសងងាសកាត់ទីប្រជុំ ។

ងងឹត គុ. ទីងងឹត, ទីដែលឥតពន្លឺ : យប់ងងឹត, ខែងងឹត ។ ភ្នែកងងឹត ឬ ងងឹតភ្នែក គឺភ្នែកដែលអន្ធ ឬ មិនសូវភ្លឺ ឬ ភ្នែកខ្វាក់ (ពាក្យគួរសម) ។ ដែលទើបនឹងកើតមិនយល់ : ងងឹតមុខ គឺដែលជាប់រវល់រកមិនឃើញ, គិតអ្វីមិនចេញ ដោយរវល់ដោះមិនស្រួល ឬ ដោយរឹងទាល់ណាដើម (កុំប្រើប្រឡំជា ល្ងិត, ល្ងិតល្ងង់) ។

ងងុយ ន. សេចក្ដីស្រពាក កើតដោយរួយស្រយាំងស្រយុតទន់ក្នុងកាយនាំឲ្យចង់ដេក : ងងុយដេក, ថ្ងៃនេះខ្ញុំធ្វើការមិនកើត ព្រោះយប់មិញខ្ញុំអត់ងងុយ ។ ប្រឹបតែចង់ដេក (មិនសូវប្រើ, ច្រើនប្រើជា ងុយ ឬ ងុយដេក, ងុយទទួលទានដំណេក) ។

ងងុល កិ. វិ. ឬ គុ. ដែលសំយុងមុខចង្រុលមិនងើប : ដើរងងុល, ស្រវឹងស្រាងងុល; ដំណើរងងុល ។ ប្រើជា កិ. ក៏បាន : កុំងងុលពេក, តំពុងងងុលខ្លាំងណាស់ ។

ងងុះ កិ. វិ. ដែលធ្វើការមមុះហើយនិយាយធ្ងរហើមៗ មិនសូវជាប់ស្នូរ : ធ្វើការងងុះពាល់ល្ងាច ។

ងងូស ឧ. ងូសរឿយៗ : ចុះខ្ទិលកន្ទិលមុះ, សព្វថ្ងៃនេះ, ស៊ីកាំប្រេ, មេសូរ គឺមិនងាស៊ីវៃ, ទៅវិញងងូសទៅសុំគេស៊ីរកលាំថ្ងៃ, មិនដឹងខ្មាសគេទេឬ ? (ត. ប្រ. ម.) ។

ងងើល ឬ ងងឿល កិ. វិ. ឬ គុ. ដែលមានកិរិយាងើបងើយបន្តិចហើយងងើល, ឈរលាំង ងងៀង ងងៀល ងងូស : ឈរងងើលដូចគេកកខ្លាស; ដំណើរងងើល ។

ងងើស ខ. សូរសំឡេងដែលឮទើសៗរឿយៗ : ឈឺងងើស (ម. ក. ងើសៗ ផង) ។

ងប់ ១ កិ. ឬ គុ. ស្រប់ងាក; មុខឹង : ជាង ៦ ខែ ហើយកងប់តែនឹងល្បែង មិនសូវមកផ្ទះសំបែងទេ ។

ងប់ ២ ន. ឈ្មោះឈើតូចមួយប្រភេទ ស្លឹកក្រពុល, ស្លឹកប្រើធ្វើជាថ្នាំស្រឡាបរំងាប់ចំហាយគ្រុនក្ដៅ ឬ ធ្វើជាបន្លែស្ល ស្រល់កំបោះ; អ្នកខ្លះហៅថា ដើមទៀនអាំ ព្រោះមានផ្កា, ផ្លែលក្ខណៈដូចទៀនអាំ ។

ងា កិ. សំដែងអាការយោលទៅ : ងាចុះ, ងាឡើង ។

ងា កិ. លើកដៃឡើងងងូ ឬ លើកដៃភាកសាងសំគុន : ងាដៃ, ងាដៃជជូ ។

ងាក កិ. បែរបញ្ឆៀង, បែរទៅ : ងាករកទិស, ងាកស្ដាំ, ងាកចុះងាកឡើង ។ ងាកចិត្ត, ងាកគំនិត គឺបែរចិត្ត, បែរគំនិត ។

ង៉ាង ន. ពាក្យសម្រាប់ប្រើជាមួយពាក្យនឹងឡើង

ឡើងជាប្រក្រតី : តឹងង៉ាង តឹងខ្លាំង, តឹងណាស់ ។

**ង៉ាងៗ** ឧ. សូរឮដោយភ័យ, ដោយគោះគ្រឿងកាយដ៏មានតាំង ឬ ឈ្មោះជាដើម (និយាយថា ង៉ាងៗ ក៏មាន) ។

**ង៉ាញ់ៗ** ឧ. សូរឮដោយថ្គាមហ៊ឹមញោញញួញ ដើម្បីការខ្ទួន ឬ ការមិនឲ្យថ្លែងទៀត តាំងពីមានហេតុចំណីដែលខ្លួនកាចមក ។

**ងាប់** កិ. ឬ គុ. ស្លាប់, តាំង; និយាយចំពោះតែអនុបាទិន្នករូប មានឈើនិងគ្រឿងចក្រជាដើម : *ឈើងាប់, ម៉ាស៊ីនងាប់, នាឡិកាងាប់* ។ បើចំពោះបាទិន្នករូបមានមនុស្សជាដើម គឺជាពាក្យគ្រោះ : *អាចោរកំណាចនោះ វាងាប់ទៅហើយ* ។ ចំពោះសត្វតិរច្ឆាន *គោងាប់, ក្របីងាប់* ។ *ងាប់គំនិត* គំនុំ, គាំងអស់ផ្លូវគិតតទៅទៀត ។ ព. ទ. ថា : *ស្លាប់គំនិត, ផុតគំនិត, តាល់គំនិត, អស់គំនិត* ។

**ងាយ** គុ. វិ. ឬ គុ. ដែលមិនក្រ, មិនពិបាក គឺដែលស្រួល, ដែលស្រណុក ធ្វើបានកើត, រកបានជាដើម : *ការងាយសោះទៅជាធ្វើមិនកើត* ។

**ងារ** ១ ន. មុខការ, ទីតំណែងផងការងារបណ្ដាស័ក្ដិ, តាមក្រសួង, បណ្ដាស័ក្ដិ, យសស័ក្ដិ, ឋានន្តរ ។ *លោកហ្នឹង មានងារជាអ្វី ? មានងារជាហ្លួងពិភក្តិអក្សរ* ។

**ងារ** ២ ន. ភាគដីល្មមកម្លាំងប្រុសធ្វើមួយពេលហើយការ : *ដីមួយងារ, ភ្ជួរស្រែមួយព្រឹកបានពីរងារ* ។ ការដែលចែកដោយមុខៗ, ដោយឡែក ក៏ហៅថា *ងារ* ដែរ : *ធ្វើការតាមមុខងារ, ធ្វើការកាន់មុខងារ, ធ្វើការកាន់ងារ, ភ្ជួរកាន់ងារ* ។

**ងារ** ៣ ឬ. ពាក្យសម្រាប់និយាយផ្សំជាមួយនឹងពាក្យ ការ : *ការងារ* គឺកិច្ចការដែលត្រូវធ្វើដោយមុខ ។

**ងារ** ន. សៀសសម្ផុរមួយប្រភេទ ក្នុងពួកត្រង : *ផ្អកងារ* ។

**ង៉ារ** ១ ន. (សំ.) ជាវិសេស; កងសព្ទហៅថា *ព្រះវេសង៉ារ* ។

**ង៉ារ** ២ ន. អំពើដោយល់ណាកស្ទឹកទឹក, មានតែស្លាបចតសាយ : *ផែកង៉ារ* ។

**ង៉ារៗ** ឧ. សូរសម្រែកឆ្មា : *ឆ្មាស្រែកង៉ារៗ* ។

**ងាស** កិ. ប្រកាសចេញ : *ងាសដៃ, ងាសជើង* ។

**ងាស់** កិ. ឬ គុ. ចាស់សាវៃ, ស្ទាត់ខ្លួនតាំងខ្លួន : *ងាស់ដៃ, ដៃងាស់* ។ *គំនិតងាស់* ឬ *ងាស់គំនិត* ចេះគិតពិចារណាឃើញជ្រះ ទេះ ។ *ការងារងាស់*



ការងារដែលតាំងប្រព្រឹត្តទៅមិនស្រួល ។ *ងាស់ស៊ីដី* ស៊ីដីតាំង មិនភបសា ។ល។

**ងុកង៉ក់** ១ កិ. ងោកងោក, ធ្វើអាយាញ៉ុកញ៉ាក់ (ញ៉ុកញ៉ាក់) ។

**ងុកង៉ក់** ២ កិ. វិ. ដែលមានដំណើរញ៉ុកញ៉ាក់ : *ដើរងុកង៉ក់, ធ្វើងុកង៉ក់* ។

**ងឹក** ឬ. ពាក្យសម្រាប់និយាយផ្សំជាមួយនឹងពាក្យងាក : *ងឹកងាក, ដើរងឹកងាក; ដំណើរងឹកងាក* ។

**ងើងើ** ឬ **ងែងើ** កិ. វិ. ឬ គុ. ដែលគ្រាន់តែឿសរាទៅមក : *ធ្វើក្បាលងើងើ* ។

**ងើរ** ន. (ចិ.) ផ៉ាបិន, ល្ខោនចិន : *ចិនលេងងើរ, ទៅមើលងើរ* ។

**ងឺល** ឧ. សូរឮដោយថ្គាមហ៊ឹម : *ថ្គាមហ៊ឹមងឺលៗ* ។

**ងុក** ឧ. សូរទន្ទ្រាំ, សូរអួល ហើយញ៉ើក ឬ សូរញ៉ើកការមហ្មត : *ញ៉ើកងុកៗ* ។

**ងឺៗ** ឧ. សូរគ្រហឹមស្រាលៗ ។

**ងុតៗ** ឧ. សូរឮដោយវត្ថុពីរសៀតគ្នា ។

**ងុសៗ** ឧ. សូរសម្រែកថ្ងូរនៃមនុស្ស ឬ សត្វដែលឈឺធ្ងន់ជិតផុតខ្យល់ដង្ហើម : *ស្រែកងុសៗ* ។

**ងុំ** ឧ. សូរឮដោយថ្គាមបាក់ : *ថ្គាមបាក់ងុំៗ*

**ង៉ុមៗ** ឬ **ងុមៗ** ឧ. សូរសំឡេងខ្លាគ្រហឹមការពារ : *ខ្លាគ្រហឹមការពារកូនងុមៗ* ។

**ងុងែក់** គុ. ចាស់ជរាក្រាំក្រាង, ដែលទ្រមខ្លាំង មានដំណើរដុំដុលដម្រេក : *ចាស់ងុងែក់* (ពាក្យសាមញ្ញ) ។ (ម. ព. *ហួនហិក* ផង) ។

**ង៉ុលៗ** ឧ. សូរសំឡេងស្រទុក ឬ និយាយបុងច្រមុះ : *ឮសូរង៉ុលៗ, និយាយង៉ុលៗ* ។

**ងូងៗ** ឧ. សូរគងធំ; សូរកន្ធក់ហើរជាដើម ។

**ង៉ូង** ឧ. សូរឮគ្រលួចស្រួចឡើង : *សំឡេងង៉ូងៗ*

**ងូត** កិ. ស្រោចទឹកជម្រះកាយខ្លួនឯង : *ងូតទឹក* ។ ផ្ទុំកាលប្រើជាតាមសព្ទ : *ភ្លៀងមួយងូត* គឺភ្លៀងល្មមទទឹកខ្លួនផ្ដាច់ផ្តួល ឬ ល្មមងូតបាន ។

**ង៉ូតៗ** ឧ. សូរឮដោយថ្ងូរ, ដោយឈ្លក់មានសំឡេងខ្លួបស្រួចឮឆ្ងាយៗ ។

**ង៉ូវៗ** ឧ. ឬ កិ. វិ. សូរសំឡេងនិយាយអត្រ ឬ ក្នុងច្រមុះរៀបរៀប : *ថ្ងូរង៉ូវៗ, និយាយង៉ូវៗ* ។

**ងូសៗ** ឧ. សូរមនុស្សនិយាយគ្នាតិចៗ : *និយាយគ្នាងូសៗ* (ម. ព. *ងឹសៗ* ផង) ។

**ងើក** *កិ.* ងក : *ងើកមើល, ងើកក, ងើកមុខ* ។ មាក់ស្ងួតមុខឡើងរឿយៗ : *ខចង់ងើយ! ខ្ញុំឈឺក្រេមជាង ៣ ថ្ងៃហើយ, មេគួចហ៊ីង កម្មិចដែលមកងើកខ្ញុំផងទេ!* ។ ប្រើជាបរិវារសព្ទជាមួយនឹងពាក្យ *ស្ងើក* ក៏បាន : *កម្មិចដែលស្ងើកងើកឯងនោះ* ។

**ងើប** *កិ.* ងើយឡើង : *ងើបក្បាលឡើង* ។ *ឥតក្លាសតាល់តែងើបមុខមិនរួច* និយាយសំដៅដល់តែអ្នកមុខក្រប់ ។ ប្រកប : *ងើបឡើង, ឈឺធ្ងន់ងើបមិនរួច* ។

**ងើយ** *កិ.* បែរមុខទៅលើ : *ងើយមើលមេឃ* ។ *គុ.* ដែលមានលំងើយ ។

**ងឿ** *ន.* (ម.) ផ្កាក្រាស់ធំខ្នុរ ពរ ឬ បីសន្លឹក តម្រៀបគ្នាលើដើមត្រួ : *ផ្កាងឿ* ។

**ងឿក** *កិ.* (ម.) ក្ដិចគេចមិនត្រូវ : *ក្មេងនេះងឿកអ៊ីម្ល៉េះ ? ងឿកងើ* ងឿកលយលែង; ងឿកក្លិចក្លក់ ។

**ងឿង ១** *កិ.* ឬ *គុ.* ងេងងោង, ច្រឡំ : *កំពុងតែគិត ស្រាប់តែងឿងគិតមិនឃើញ* ។ *កុំងឿងដោយខ្យល់* កុំងឿងព្រោះសំដីគេនិយាយក្បត់ក្លែងគំនិត ។ *កុំងឿងដោយខ្យល់ កុំខកពាក្យពល កុំខ្វល់ដោយស្រី កុំកាន់ពិសយន៍ គប់ខ្លួនស្ត្រី សមណជនជី កុំខ្សត់ត្រូវ* (សាស្ត្រាច្បាប់កេរព្រះរាជនិពន្ធនៃព្រះរាជសម្ភារ) ។ *ងឿងឆ្ងល់* ងឿងត្រៅគិតតែគំនិតគិតអ្វីក៏មិនឃើញ ។ *ងឿងឆ្ងល់* ឆ្ងល់ងឿងគំនិតគិតមិនឃើញ ។ *ងឿងស្រឡាំងកាំង* ស្រឡាំងកាំងកាំងគំនិតប្រកបដោយការភ្ញាក់ផ្អើលផង ។ល។

**ងឿង ២** *គុ.* ដែលឆ្ងល់ក្នុងក្បាល, ដែលឈឺស្ពឹកក្នុងក្បាល : *ឈឺក្បាលងឿង* ។

**ងៀង** *ន.* សន្ធាក់, ឈ្នៀង : *ងៀងសន្ទូច, ងៀងឡូក* ។

**ងៀក** *ន.* វត្ថុក្រៀមដែលប្រឡាក់អំបិលហាលថ្ងៃ; ប្រើតែប្រើចំពោះតែត្រី ឬ សាច់ : *ត្រីងៀត, សាច់ងៀត* ។ ពាក្យប្រៀប *គុ.* ឬ *កិ. វិ.* ងៀតស្រាំង, ស្រីង ដោយធ្វើការហាលថ្ងៃឥតមានសម្រាក : *ធ្វើការហាលងៀត* ។

**ង៉ែកៗ** *ន.* សូរសំឡេងក្អួក ។

**ងេកងោក** *គុ.* ឬ *កិ. វិ.* ដែលត្រលែងយោលៗ : *ដំណើរងេកងោក; ដើរងេកងោកៗ* ។

**ងេងងោង** *គុ.* ដែលច្រើនភ្លេច, ច្រើនភ័ន្តស្មារតី : *ចាស់ងេងងោង; គំនិតងេងងោង* ។



**ងេរងើ** *កិ. វិ.* ឬ *គុ.* (ម. ព. ងើរងើ) ។

**ង៉ែតៗ** *ន.* សូរឮដោយអ៊ឺរសង្កៀតធ្មេញ : *សូរខែរងើតៗ* (ម. ព. ង៉ឺតៗ ផង) ។

**ង៉ែវ ១** *គុ.* ដែលមានសូរស្រួយស្តួចច្ចូលច្បារ : *សំឡេងង៉ែវ, មនុស្សសំឡេងង៉ែវ* ។

**ង៉ែវ ២.** *ន.* សូរឮដោយនិយាយរង៉ែវខ្លួនៗ : *និយាយង៉ែវៗ* ។

**ង៉ែសៗ** *ន.* សូរសំដីនិយាយចុងច្រមុះ ដោយមានកម្លាំងខ្សោយហើយមានហក់ផង : *សំឡេងង៉ែសៗ, និយាយង៉ែសៗ* (ម. ព. ង៉ើស ផង) ។

**ង៉ែះៗ** *ន.* សូរសំឡេងក្មេងកោះរ៉េះ : *ក្មេងអណ្ដើក ឮសូរង៉ែះៗ* ។

**ង៉ៃង៉ៃ** *ន.* សូរសំឡេងក្មេងយំ ។

**ង៉ៃង៉ៃរ** *កិ. វិ.* វិលវល់ស្ទាក់ស្ទើរ, ករកករមិនដាច់ស្រេច : *ដើរង៉ៃង៉ៃរ, និយាយង៉ៃង៉ៃរ* ។

**ង៉ៃក** *ន.* សំដីហៅក្មេងតូច (ប្រើតាមទម្លាប់ស្រុក) : *កូនង៉ៃក* (កូនខ្ញុំ) : *អាង៉ៃក, មេង៉ៃក* (អាណុច, អាតាង, អាក់; មេតាង, មេក់) ។

**ង៉ៃ** *ន.* ថ្ងៃ ។ ពាក្យសាមញ្ញ ជាគ្រាមភាសា : *តាម តែថ្ងៃណាក៏បាន* ។

**ងោក** *កិ.* ក្រឡាប់ទៅដោយងុយដេក; ទម្លាក់ក្បាល ទាំងខ្លួនទៅក្រោយ : *តាត់អង្គុយងោកងោក* ។

**ង៉ោកង៉ាក** *ន.* សូរសត្វក្រោហ្មណ៍សង្ឃ : *ក្រោហ្មណ៍សង្ឃពេលរក្សាឡើងដើរង៉ោកង៉ាក* ។

**ងោង ១** *ន.* សាច់ឈើដែលនៅទំពូលៗ កំពុងផ្កាហើយ ទម្លាក់ចុះក្នុងដេះដើម្បីយកជាតិប្រៃ, ងាក់ក្នុងនៅស្រស់សម្រាប់ ទុកចរិកោតឈូរថ្ងៃឈូរទៀត; ផ្ទាល់តេយកត្រីមកធ្វើដែរ តែ ច្រើនយកព្រីព្រា; ច្រើននិយាយថា *ងៀតងោង* ពិនិយាយ ភ្ជាប់ជាងៀតជាងោង (ម. ព. *ងៀត* ផង) ។

**ងោង ២** *គុ.* ដែលស្ទើរបាត់ស្មារតី, ដែលងឿងយ៉ាងខ្លាំង : *ត្រូវក្បាលងោង* (ម. ព. *ងឿង ២* គុ. ផង) ។

**ងោង ៣** *កិ.* ឬ *គុ.* ដែលកំបាំងគំនិតគិតមិនចេញ : *ការច្បាប់នេះនៅជាងោងគំនិតគិតមិនឃើញ* (ម. ព. *ងឿង ១ កិ.* ឬ *គុ.* ផង) ។

**ង៉ោង ១** *ន.* ឬ *កិ. វិ.* ដែលឮដោយយំខ្លាំង : *ស្រែកយំង៉ោង* ។

**ង៉ោង ២** *គុ.* ដែលស្ពុយខ្លាំង, ស្អុយឡប់ : *ស្អុយង៉ោង* ។

ឆ្អោបៗ *កិ. វិ.* ដែលទទួលតែលេវ រៀបរ៉ូវ : *ស្អុះ ឆ្អោបៗ* ។

ឆ្អោរ *ន.* ឈ្មោះមួយប្រភេទក្នុងពួកត្រីស្លឹកឫស្សី ជាប្រភេទប្រាក់ ប្រាំ ។ *ការឆ្អោរ / ភាណ្ឌ* (ព. បុ. ម.) ។

ឆ្អោះៗ *ទ.* សូរសំឡេងស្អួតស្អាញ ចេញពីច្រមុះ : *និយាយឆ្អោះៗ* ។

ឆ្អៅ *គុ.* ពាក្យសម្រាប់ប្រើជាជំនួយពាក្យក្រហម ឲ្យឃើញច្បាស់ថាក្រៃ : *ក្រហមឆ្អៅ* ពិ. ក្រហមច្រាលឆ្អាំង, ក្រហមឆ្អៅ (ម. ព. *ឆ្អាំង* ផង) ។

ឆ្អ៉ៅ *គុ.* ដែលរលោងផូរ ស្រមោលបាន : *ធាត់ឲ្យ ស្មើរលោងឆ្អ៉ៅ* ពិ. ធាត់ឲ្យស្មើរលោងផូរស្រមោល បាន ។

ឆ្អំ *គុ.* ក្ដៅល្អ, ឆ្អិន : *ឆ្អាយឆ្អំ* ។ *ក្ដៅឆ្អំ* ក្ដៅ សព្វសព៌ាង្គកាយ ហាក់ដូចជាឆាយឆ្អំ ។ *ទឹកឆ្អំ* ទឹកដាំបាយជាមិន មិនស្អាត់ ។

ឆ្អុំ *ន.* កន្ទក់ ឬ កៀងកញ្ជើកន្ទុះធំសម្រាប់ដាក់ឲ្យកើប ដាប់ : *ឆ្អុំកញ្ជើ* ។

ឆ្អុំៗ ១ *កិ. វិ.* ជាមិនឆ្អាល់ : *និយាយឆ្អុំៗ* ។

ឆ្អុំៗ ២ ទ. សូរផ្ទុះប្រាំភ្លា ឬសូរស្រស់ក្រៀមអង្គ *ឆ្អុំៗ* ដែរ ។

ឆ្អាំង ១ *គុ.* ដែលក្រហមចាស់ : *ក្រហមឆ្អាំង* (ម. ព. *ឆ្អៅ, ឆ្អៅ* ផង) ។

ឆ្អាំង ២ *ន.* ឈ្មោះត្រីអណ្ដែងមួយប្រភេទមានសាច់ ហាប់ ក្បាលធំប្រវែង សម្បុរខ្មៅក្រីអណ្ដែងទន់ : *ត្រីអណ្ដែង ឆ្អាំង មានតួបជាងត្រីអណ្ដែងទន់* (ម. ព. *អណ្ដែង* ទៀតផង) ។

ឆ្អុំង ឬ ឆ្អុំងៗ ទ. សូរឮដោយផ្ទុះការ ឬ ដោយ ក្លួងឮស្អួបយំខ្លាំង : *យំឆ្អុំងៗ* ។